# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាជាមួយអដ្ឋិធាតុរបស់សន្ត លូវីស និងសន្តី ហ្សេលី ម៉ាតាំង
# កំពង់សោម ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩
# ឪពុកម្ដាយដែលអប់រំណែនាំកូនឲ្យកូនស្គាល់ស្ថានបរមសុខ

**អត្ថបទទី១៖ ថេស្សាឡូនិក ទី១ ៣,៧-១៣**

ហេតុនេះ បងប្អូនអើយ ជំនឿរបស់បងប្អូនបានធ្វើឲ្យចិត្តយើងបែរជាធូរស្រាលវិញ ទោះបីយើងពិបាកចិត្តគ្រប់យ៉ាង និងមានទុក្ខវេទនាយ៉ាងណាក្ដី។ ១ថស ៣,៧

**ដំណឹងល្អ៖ ម៉ាកូស ៦,១៧-២៩**

ដ្បិតព្រះបាទហេរ៉ូដខ្លាចលោកយ៉ូហាន ព្រោះទ្រង់ជ្រាបថា លោកជាមនុស្សសុចរិត និងជាអ្នកដ៏វិសុទ្ធ។ ដូច្នេះ ទ្រង់ការពារលោក។ កាលទ្រង់ព្រះសណ្ដាប់ពាក្យលោកយ៉ូហាន ទ្រង់សព្វព្រះហឫទ័យជាខ្លាំង តែទ្រង់រារែកមិនដឹងជាត្រូវគិតយ៉ាងណា។ មក ៦,២០

បងប្អូនជាទីស្រឡាញ់!

សន្ត យ៉ូហានបាទីស្ទ ជាបងជីដូនមួយរបស់ព្រះយេស៊ូ នៅពេលយ៉ូហានបាទីស្ទកើតនៅពេលនោះម្ដាយគាត់ចាស់ហើយ យាយអេលីហ្សាប៉ែតមានផ្ទៃពោះដោយសារការអស្ចារ្យរបស់ព្រះជាម្ចាស់។ ឪពុកគាត់ឈ្មោះ ហ្សាការី គាត់គ(និយាយមិនកើត)អស់៩ខែអំឡុងពេលប្រពន្ធគាត់មានផ្ទៃពោះ ដោយសារគាត់មិនមានជំនឿលើព្រះជាម្ចាស់គ្រប់គ្រាន់លើការអស្ចារ្យរបស់ព្រះអង្គ។ នៅពេល យ៉ូហានបាទីស្ទ កើតគេសុំឲ្យលោក ហ្សាការី ដាក់ឈ្មោះឲ្យកូនគាត់បានសរសេរកូននេះឈ្មោះយ៉ូហាន ក្រោយមកប្រជាជនគេសួរគ្នាទៅវិញទៅមក **តើកូននេះនៅថ្ងៃអនាគតនឹងទៅជាយ៉ាងណា?** ថ្ងៃនេះ យើងមានចម្លើយដែលចេញពីបបូរមាត់របស់ស្ដេចហេរ៉ូដ ដែលថា "**លោកជាមនុស្សសុចរិត និងជាអ្នកដ៏វិសុទ្ធ**"។ ដូច្នេះ ពីកុមារភាពរហូតដល់យ៉ូហានបាទីស្ទបានទទួលមរណភាព បន្តិចម្ដងៗគាត់បានរីកចម្រើននៅក្នុងភាពដ៏វិសុទ្ធ និងទៅជាមនុស្សសុចរិត។ នៅពេលយើងឆ្លងទន្លេថ្មីៗ ឬយើងមានកូនខ្ចី យើងសួរខ្លួនឯងថា **តើនៅថ្ងៃអនាគតកូនខ្ញុំនឹងទៅជាកូនដូចម្ដេច?**

ថ្ងៃនេះ យើងពោរពេញដោយអំណរសប្បាយ ដោយបានទទួលស្វាគមន៍ធាតុរបស់សន្តលូវីស និងសន្តី ហ្សេលី ទាំងពីរនាក់បានស្លាប់ជាង១៥០ឆ្នាំមុន នៅក្នុងឆ្នាំ២០០៥ ព្រះសហាគមន៍បានទទួលស្គាល់ថា ហ្សេលី និងលូវីស ជាគ្រួសារដ៏វិសុទ្ធ។ ដូច្នេះ ថ្ងៃនេះគឺជាឱកាសមួយដើម្បីរិះគិត និងដើម្បីស្ដាប់របៀបទាំងពីរនាក់ បានអប់រំ ថែរក្សា យកចិត្តទុកដាក់ចំពោះកូនៗរបស់គាត់។ នៅពេលទាំងពីរនាក់ចាប់ផ្ដើមមានកូន គេចាប់ផ្ដើមគិតថាអនាគតកូនខ្ញុំទៅជាកូនយ៉ាងណា នៅ

ក្នុងកូនស្រី៥នាក់ដែលនៅរស់មានសន្ដីម្នាក់ គឺសន្ដី តេរេសានៃព្រះកុមារយេស៊ូ ដែលព្រះសហគមន៍ទទួលស្គាល់។ នៅពេល ហ្សេលី គាត់និយាយអំពីការអប់រំកូនរបស់គាត់ គាត់និយាយថា "**ខ្ញុំអប់រំណែនាំកូនខ្ញុំ ដើម្បីឲ្យកូនខ្ញុំភ្ជាប់នឹងស្ថានបរមសុខ**" គាត់បានថែមថា "**ខ្ញុំចង់មានកូនយ៉ាងច្រើន ដើម្បីឲ្យកូនខ្ញុំអាចទៅជាសន្ដនិងសន្ដី**"។ គាត់គិតដូចនេះ "**ខ្ញុំចង់ឲ្យកូនខ្ញុំទទួលការសិក្សាអប់រំដ៏អស្ចារ្យ ដើម្បីឲ្យកូនខ្ញុំទៅជាសន្ដសន្ដី ទៅជាអ្នកដ៏វិសុទ្ធ**"។ លូវីស គាត់និយាយថា "**នៅក្នុងជីវិតរបស់យើង យើងជោគជ័យនៅក្នុងសង្គមមិនសំខាន់ប៉ុន្មានទេ យើងមានសុភមង្គលឆាប់ៗនៅក្នុងជីវិតរបស់យើងមិនសំខាន់ប៉ុន្មានទេ ប៉ុន្ដែសំខាន់គឺពីមួយថ្ងៃទៅមួយថ្ងៃយើងរស់នៅសម្រាប់ព្រះជាម្ចាស់**"។ នេះជាគម្រោងការណ៍របស់គាត់សម្រាប់កូនគាត់ គាត់ដឹងថាកូនគាត់មានការងារធ្វើអស្ចារ្យ មានលុយចាយច្រើន មានស្នាដៃពិសេសនៅក្នុងសង្គមមិនសំខាន់ជាងគេ សំខាន់បំផុតឲ្យកូនគាត់រស់នៅសម្រាប់ព្រះជាម្ចាស់ ដោយសារជាព្រះជាម្ចាស់បានបង្កើតយើង។

ហេតុនេះហើយ ដើម្បីឲ្យកូនគាត់ស្រឡាញ់ព្រះជាម្ចាស់ ឪពុកម្ដាយនេះបានធ្វើឲ្យកូនគាត់ស្គាល់ព្រះជាម្ចាស់ ពីមួយថ្ងៃទៅមួយថ្ងៃទាំងពីរនាក់យកចិត្តទុកដាក់ព្យាយាម ដើម្បីឲ្យកូនមើលឃើញព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ មើលឃើញសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់យ៉ាងជាក់ស្ដែង។ ព្រឹកឡើងនៅពេលកូនភ្ញាក់ពីដេកគេនិយាយទៅកូនគេថា "**ថ្ងៃនេះសូមផ្ញើសេចក្ដីស្រឡាញ់ដួងចិត្តទៅលើព្រះជាម្ចាស់**"។ ពេលម្ដាយកំពុងពាក់អាវឲ្យកូន នៅពេលនោះម្ដាយគាត់និយាយអំពីព្រះយេស៊ូ និយាយអំពីព្រះជាម្ចាស់ និយាយអំពីព្រះនាងម៉ារី និយាយអំពីសន្ដយ៉ូសែប និយាយអំពីសន្ដបុគ្គលទាំងឡាយ។ ក្រោយមក គេទាំងអស់គ្នាជួបជុំគ្នាដើម្បីអធិដ្ឋានរាល់ពេលព្រឹក គេអធិដ្ឋានឱព្រះបិតា បពិតព្រះនាងម៉ារី នេះជារបៀបសម្រាប់ការអប់រំពីឪពុកម្ដាយ។

ហ្សេលី ដែលគាត់ជាជាងប៉ាក់អាវគាត់ធ្វើនៅផ្ទះ គាត់មានកូនតូចនៅជាមួយគាត់ពេលកំពុងធ្វើការ គាត់និយាយរឿងអំពីព្រះយេស៊ូដូចជារឿងនិទាន ដើម្បីឲ្យកូនគាត់ស្ដាប់។ កូនៗរបស់គាត់បានចូលក្នុងរឿងព្រះយេស៊ូអស់ហើយ គាត់និយាយអំពីស្ថានបរមសុខ និយាយអំពីជីវិតនិងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់។ នៅក្នុងទូសៀវភៅរបស់គេ គេមានសៀវភៅទាក់ទងអំពីជីវិតរបស់សន្ដសន្ដីបុគ្គល គាត់អានរឿងសន្ដសន្ដីយ៉ាងច្រើន ដើម្បីឲ្យកូនពេលគេចាប់ផ្ដើមចេះអានឲ្យគេអានខ្លួនឯងដែរ។ នៅពេលយប់ មុនចូលដេកគ្រួសារទាំងអស់ជួបជុំគ្នាម្ដងទៀត ដើម្បីអធិដ្ឋានជាលក្ខណៈគ្រួសារ នេះជាគំរូល្អសម្រាប់យើងរាល់ពេលល្ងាចមានឱកាសមួយ ដើម្បីអធិដ្ឋានជាមួយកូនៗ។ ថ្ងៃអាទិត្យ គេទៅចូលរួមអភិបូជាជាលក្ខណៈគ្រួសារ គេទៅជាមួយឪពុកម្ដាយនិងកូនស្រីទាំង៥នាក់។

នៅពេល លោកបូជាចារ្យកំពុងទេសនា សន្តី តេរេសា សម្លឹងមើលមុខឪពុកគាត់ ដោយសារឪពុកគាត់ស្តាប់ អធិដ្ឋានជាមួយព្រះជាម្ចាស់។ គាត់សម្លឹងមើលឪពុកគាត់ផ្ទាល់ ដូចជាមានអ្វីពិសេស របៀបដែលគាត់អធិដ្ឋាន របៀបដែលគាត់ជាប់ជាមួយព្រះជាម្ចាស់។ សន្តី តេរេសា និយាយថា "**នៅពេលដែលគាត់នឹករលឹកដល់សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដែលជាព្រះបិតា ភ្លាមគាត់នឹកឃើញឪពុកគាត់ ឪពុកគាត់បីដូចជាព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់សម្រាប់គាត់ ឪពុកគាត់ប្រៀបបីដូចជាសេចក្តីស្រឡាញ់យ៉ាងជាក់ស្តែងរបស់ព្រះជាម្ចាស់សម្រាប់គាត់**"។ សន្តី តេរេសា គាត់បានស្គាល់សេចក្តីស្រឡាញ់ ធម៌មេត្តាករុណា ព្រះហឫទ័យប្រណីសណ្តោសរបស់ព្រះជាម្ចាស់ តាមរបៀបឪពុកម្តាយគាត់។ ម្តាយគាត់ស្លាប់ នៅពេលតេរេសាមានអាយុ៩ឆ្នាំ តេរេសាគាត់នឹកឃើញពេលគាត់ធ្វើខុសគាត់ទៅសុំទោសអ្នកម្តាយ និងម្តាយគាត់ចាប់អោបគាត់ថើបគាត់ និងឲ្យញ៉ាំស្ករសូកូឡា។ ពេលគាត់នឹកឃើញដល់ព្រះជាម្ចាស់ គាត់នឹកឃើញដល់របៀបម្តាយបានស្រឡាញ់គាត់ លើកទឹកចិត្តគាត់ ពេលគាត់ធ្វើខុសពេលគាត់ទៅសុំទោសម្តាយថើបគាត់អោបគាត់យ៉ាងខ្លាំងឲ្យស្ករគ្រាប់សូកូឡាទៀត។

ឪពុកម្តាយរបស់សន្តីតេរេសា គឺហ្សេលី និងលូវីស ដែលយើងមាននៅទីនេះគេមិនចង់ឲ្យកូនគេពោរពេញដោយសីលធម៌ ដើម្បីទៅជាមនុស្សពិសេសនៅក្នុងសង្គម។ ប៉ុន្តែគេអប់រំកូនកុំឲ្យកូននិយាយកុហក់ កុំឲ្យកូនពោរពេញដោយអំនួតនៅក្នុងខ្លួន កុំឲ្យកូនជាមនុស្សដែលចង់បាននេះបាននោះអត់មានន័យអត់មានប្រយោជន៍។ ផ្ទុយទៅវិញ គេចង់ឲ្យកូនគេយកចិត្តទុកដាក់រស់នៅយ៉ាងសាមញ្ញ ដើម្បីឆ្លើយតបទៅនឹងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ យើងត្រូវការនឹកឃើញព្រះជាម្ចាស់ស្រឡាញ់យើងខ្លាំងណាស់ ដូច្នេះយើងធ្វើដូចម្តេចដើម្បីឆ្លើយតប ដើម្បីដឹងគុណ ដើម្បីបង្ហាញសេចក្តីស្រឡាញ់ដល់ព្រះជាម្ចាស់ ដោយដឹងថាព្រះជាម្ចាស់ស្រឡាញ់យើង។ ដូច្នេះគេខិតខំអប់រំកូនគេ ដើម្បីឲ្យកូនគេជាប់នឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ គាប់នឹងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់។ ហ្សេលី ជាម្តាយម្នាក់ដែលតឹងរឹងមែនទែន ពេលកូនយំគាត់ពន្យល់កូននេះមានប្រយោជន៍ នេះអត់ប្រយោជន៍ នេះល្អ នេះមិនល្អ ជាម្តាយដែលខិតខំអប់រំកូនឲ្យកូនរីកចម្រើននៅក្នុងជីវិតផ្ទាល់ និងនៅក្នុងទំនាក់ទំនងជាមួយព្រះជាម្ចាស់។ គាត់មិនអប់រំកូនដោយពិន័យ ដោយវ៉ៃ ដោយស្តីឲ្យ ប៉ុន្តែគាត់អប់រំកូនដោយធ្វើជាគំរូ។ សន្តី តេរេសា ធ្លាប់និយាយថា "**ខ្ញុំតែងមើលឪពុកម្តាយកំពុងអធិដ្ឋាន ខ្ញុំយល់ភ្លាមអំពីរបៀបដែលសន្តសន្តីបុគ្គលអធិដ្ឋាន**" សន្តីតេរេសាគាត់នឹកឃើញនេះច្បាស់។ នៅពេលឪពុកគាត់ បានដើរតាមផ្លូវជួបជាមួយអ្នកសុំទាននៅពេលនោះគាត់បានលុតជង្គង់ ដើម្បីឲ្យអ្នកសុំទាននេះឲ្យពរមកគាត់នេះ ដោយដឹងថានៅក្នុងអ្នកសុំទាននេះមានព្រះយេស៊ូផ្ទាល់។

ដូច្នេះ យើងអាចនិយាយថាឪពុកម្ដាយរបស់សន្តី តេរេសា បានយកចិត្តទុកដាក់អប់រំកូនដើម្បីឲ្យកូនពីមួយថ្ងៃទៅមួយថ្ងៃស្គាល់ និងស្រឡាញ់ព្រះយេស៊ូយ៉ាងច្បាស់លាស់។ ប៉ុន្តែ គាត់យល់ថាកូននេះជាកូនរបស់យើងមែន ប៉ុន្តែជាកូនដែលព្រះជាម្ចាស់បានបង្កើត កូននេះមានសេរីភាព គេមិនដែលជំរុញឲ្យកូនគេចូលជាអ្នកបួសទេ។ ប៉ុន្តែ កូនស្រីទាំង៥នាក់របស់ពួកគេបានចូលធ្វើជាដូនជី ទាំងដែលឪពុកម្ដាយអត់មានគម្រោងការណ៍នោះទេ។ នៅពេលកូនសុំដើរលេងគេអនុញ្ញាតឲ្យដើរលេង ពេលមានជប់លៀងគេអនុញ្ញាតឲ្យទៅ ជាពិសេសសន្តីតេរេសាទៅជាមួយឪពុកដល់ទីក្រុងរ៉ូមនិងជួបជាមួយសម្ដេចប៉ាបទៀត។ ដូច្នេះ គេឲ្យកូនគេនៅជាប់ក្នុងផ្ទះបិទទ្វារ និងនៅតែអធិដ្ឋានទេ តែកូនគេមានសិទ្ធិដើរលេងជាមួយមិត្តភក្តិ ស្គាល់ពិភពលោក។ ដោយដឹងថា កូននេះយើងបានបង្កើតគេពិតមែន ប៉ុន្តែគេទទួលជីវិតពីព្រះជាម្ចាស់។ ហេតុនេះហើយឪពុកម្ដាយបានអប់រំគេដើម្បីយកចិត្តទុកដាក់ដោយបើកទ្វារនៃជីវិតដែលទទួលពីព្រះជាម្ចាស់ផ្ទាល់ មានន័យថាបើកទ្វារនៃព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ឲ្យកូនគាត់ នេះជារបៀបដែលគាត់ទាំងពីរនាក់បានអប់រំកូន។

យើងអរព្រះគុណព្រះជាម្ចាស់ នៅទីនេះយើងមានឪពុកម្ដាយ យើងមានតាយាយ យើងមានយុវជនយុនារីមួយចំនួនអនាគតទៅជាឪពុកម្ដាយដែរ។ នេះជាពេលវេលាដើម្បីអធិដ្ឋានដើម្បីគិត តើយើងធ្វើយ៉ាងម៉េចដើម្បីទៅជាឪពុកម្ដាយដែលចេះអប់រំកូន ណែនាំកូន ឲ្យកូនយើងភ្ជាប់ជាមួយព្រះជាម្ចាស់នៅក្នុងសេរីភាព និងពោរពេញដោយសេចក្ដីសុខសាន្ត ដោយសារសេចក្ដីសុខសាន្តនេះមកពីព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់។ អាម៉ែន៕